**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានៈ និងប្តូរឈ្មោះសាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម ទៅជា វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លិខិតលេខ ៨២០ កប ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៨

## សម្រេច

**មាត្រា ១ :** អនុញ្ញាតឱ្យដំឡើងឋានៈ និងប្តូរឈ្មោះសាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម ទៅជា " វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម " ហៅកាត់ " វ.ប.ឧ " និងជាភាសាអង់គ្លេស ( Industrail Technical Institute )

ហៅកាត់ ( I.T.I ) ។ វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្មនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**មាត្រា ២ :** វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម មានភារកិច្ចធ្វើការបណ្តុះបណ្តាល :

-ថ្នាក់វិញ្ញាបនបត្រ បណ្តុះបណ្តាលរយៈពេលខ្លី ក្រោម ១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ

-ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល ១ឆ្នាំ, ២ឆ្នាំ, ៣ឆ្នាំ

-ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ក្រេឌីត

-ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ក្រេឌីត ។

**មាត្រា ៣ :** ចំពោះមុខ វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម មានរចនាសម្ព័ន្ធដូចខាងក្រោម :

១-ការិយាល័យរដ្ឋបាល និងបុគ្គលិក

២-ការិយាល័យហិរញ្ញវត្ថុ និងផែនការ

៣-ការិយាល័យអប់រំបណ្តុះបណ្តាល

៤-ការិយាល័យសេវាកម្ម និងផលិតកម្ម

៥-ដេប៉ាតឺម៉ង់វិស្វកម្មយន្ត

៦-ដេប៉ាតឺម៉ង់វិស្វកម្មលោហៈ

៧-ដេប៉ាតឺម៉ង់លោហៈបន្ទះបន្ទារ

៨-ដេប៉ាតឺម៉ង់បរិក្ខារត្រជាក់

៩-ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើកដេប៉ាតឺម៉ង់ ឬសាខា ឬឯកទេសផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៤ :** លក្ខខណ្ឌទទួលសិស្សឱ្យចូលរៀន :

-ថ្នាក់វិញ្ញាបនបត្រ : បេក្ខជនទាំងពីរភេទជាសិក្ខាកាមសិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ

-ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ : បេក្ខជនទាំងពីរភេទបានរៀនចប់ថ្នាក់ទី ៩ នៃមធ្យមសិក្សាបឋមភូមិ

-ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង : បេក្ខជនទាំង ២ភេទ មានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត ៣ ឬបានប្រឡងជាប់ ឬថ្នាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

-ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ : បេក្ខជនទាំង ២ភេទ មានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀន នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**មាត្រា ៥ :** នាយកនៃវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម មានបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាន និងមាននាយករង មួយចំនួន ជាជំនួយការតាមការចាំបាច់ ។

វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦ :** វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម កាន់កាប់ និងប្រើប្រាស់ប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវឧបត្ថម្ភដោយថវិកាជាតិ សម្រាប់បណ្តុះបណ្តាល និងមានគណនេយ្យដោយឡែក ។

**មាត្រា ៧ :** សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម និងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ៩ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ៨ " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ